ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ : ៦៧០អយក.ប្រក

# ប្រកាស

## ស្តីពី ការបើកសាលាបឋមសិក្សា **ខត្តត្លុំល្ង**

## ជាឧបសម្ព័ន្ធរបស់សាលាបឋមសិក្សា **ថ្កុំខស្រះឡៅ**

---

### រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញព្រះរាជក្រឹត្យលេខនស-រកត ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ២១អនក្រ.ប.កចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំយុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ-បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា ជានាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

-បានពិនិត្យលិខិតរបស់គណៈកម្មការទ្រទ្រង់សាលាបឋមសិក្សា **ខត្តត្លុំល្ង** ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០២ ដោយមានចំណារឯកភាព របស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **កំពត** ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០២

-តាមយោបល់ឯកភាពរបស់ **នាយកដ្ឋានបឋមសិក្សា**

### សំរេច

<u>ប្រការ១</u> : បើកសាលាបឋមសិក្សា **ខត្តត្លុំល្ង** ជាឧបសម្ព័ន្ធរបស់សាលាបឋមសិក្សា **ថ្កុំខស្រះឡៅ** ដែលមានទីតាំងស្ថិតនៅ ភូមិ**ភន្លង់** ឃុំ **ស្តេចគង់ខាងជើង** ស្រុក **បន្ទាយមាស** ខេត្ត **កំពត** ចាប់ពីឆ្នាំសិក្សា ២០០២-២០០៣ នេះតទៅ ។

<u>ប្រការ២</u> : សាលាបឋមសិក្សា **ខត្តត្លុំល្ង** ត្រូវមានប្រធានក្រុមម្នាក់ ទទួលខុសត្រូវ រួមជាមួយនាយកសាលាបឋមសិក្សា **ថ្កុំខស្រះឡៅ** ។

<u>ប្រការ៣</u> : អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **កំពត** ការិយាល័យអប់រំ យុវជន និងកីឡាស្រុក **បន្ទាយមាស** នាយកសាលាបឋមសិក្សា **ថ្កុំខស្រះឡៅ** និង ប្រធានក្រុមសាលាឧបសម្ព័ន្ធ **ខត្តត្លុំល្ង** មានភារកិច្ចអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៣

ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

រដ្ឋលេខាធិការ

**អ៊ឹម_សិទ្ធី**

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-ក្រសួងផែនការ-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សាលាខេត្ត **កំពត**

"**ដើម្បីជូនជ្រាបជាពត៌មាន**"

-ដូចប្រការ ៣

-កាលប្បវត្តិ-ឯកសារ នា .បស